ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥.១៣-០១៨...០០៥ ប្រ.ក.ក.ព

*ថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១*
*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ទិវាប្រាក់រៀល អបអរសាទរខួបលើកទី៣៨ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ
២០ មីនា ១៩៨០ - ២០ មីនា ២០១៨

**************

នៅព្រឹកថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានរៀបចំ "ទិវាប្រាក់រៀល" ខួបលើកទី៣៨ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ (CKCC) នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ទិវាប្រាក់រៀលត្រូវបានរៀបចំឡើងក្នុងគោលបំណង៖ i/- រំឭកថ្ងៃបង្កើតប្រាក់រៀលឡើងវិញ ii/- បង្កើនការយល់ដឹងរបស់សាធារណជនអំពីសារៈសំខាន់នៃការប្រើប្រាស់ប្រាក់រៀល និង iii/- លើកកម្ពស់ស្មារតីស្រឡាញ់ប្រាក់រៀលរបស់សាធារណជន។ តំណាងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមហ៊ុន-សហគ្រាសឯកជន និងសាធារណជនទូទៅ សរុបប្រមាណ ៥០០នាក់ បានចូលរួមក្នុងកម្មវិធីនេះដោយអធិកអធម។

តំណាងភាគីពាក់ព័ន្ធមកពីក្រុមហ៊ុន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានលើកឡើងពីកំណើនគួរឱ្យកត់សម្គាល់នៃការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រតិបត្តិការអាជីវកម្ម នារយៈពេលមួយទសវត្សរ៍ចុងក្រោយ។ នៅតាមបណ្តាទីផ្សារនានារួមទាំងផ្សារទំនើប ថ្លៃទំនិញនិងសេវាត្រូវបានដាក់តាំងជាប្រាក់រៀលកាន់តែទូលំទូលាយ ហើយក្រុមហ៊ុន-សហគ្រាសឯកជនមួយចំនួនបានចាប់ផ្តើមបើកប្រាក់ខែជារៀល។ រូបិយវត្ថុក្នុងចរាចរណ៍ និងប្រាក់រៀលក្នុងប្រព័ន្ធធនាគារបានកើនឡើងជាមធ្យម ១៧,៩% និង ២៦,៦% រៀងគ្នាក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយ។

អង្គពិធីទាំងមូលបានសម្តែងការអបអរសាទរ និងបង្ហាញស្មារតីប្តេជ្ញាចិត្តខ្ពស់ក្នុងការបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលប្រកបដោយសុទិដ្ឋិនិយម ដើម្បីពង្រឹងអត្តសញ្ញាណជាតិ អធិបតេយ្យភាពរូបិយវត្ថុ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងសង្គម។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh